


## *តើសំឡេងឆ្នោតរបស់ខ្ញុំត្រូវបានគេរាប់ដែរឬទេ? កិច្ចការដែលត្រូវធ្វើបន្ទាប់ពីអ្នកបោះឆ្នោត!*

ពេលខ្លះសន្លឹកឆ្នោតរបស់អ្នកប្រហែលជាមិនត្រូវបានគេរាប់ទេ។ ការរាប់សន្លឹកឆ្នោតត្រូវបានធ្វើឡើងច្រើនថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ដូច្នេះអ្នកអាចមានពេលវេលាដើម្បីដោះស្រាយបញ្ហាមួយចំនួនចំពោះមូលហេតុដែលសន្លឹកឆ្នោតរបស់អ្នកមិនត្រូវបានគេរាប់។
នេះជាអ្វីដែលអ្នកអាចធ្វើបានដើម្បីប្រាកដថាសំឡេងឆ្នោតរបស់អ្នកត្រូវបានគេរាប់!

***ថ្ងៃបោះឆ្នោតគឺ ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020។***

**សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមាន/ផ្ញើតាមសំបុត្រ**

1. សូមតាមដានសំបុត្ររបស់អ្នក/សម្រាប់អ្នកបោះឆ្នោតអវត្តមានដើម្បីប្រាកដថាសន្លឹកឆ្នោតនោះត្រូវបានគេរាប់។ អ្នកអាចតាមដានព័ត៌មានរបស់រដ្ឋនីមួយៗនៅលើគេហទំព័រ www.ballotready.org។
    a. សូមទូរសព្ទទៅខ្សែទូរសព្ទទាន់ហេតុការណ៍ **1-888-API-VOTE** (1-888-274-8683) បើអ្នកត្រូវការជំនួយ។ ជំនួយត្រូវបានផ្តល់ជាភាសាអង់គ្លេស បង់ហ្គាលី ចិនកាតាំង ហិណ្ឌី កូរ៉េ ចិនកុកងឺ តាកាឡុក វៀតណាម និងអ៊ើឌូ។
    b. **សូមឆាប់ចាប់ផ្តើមតាមដាន** – ជារឿយៗពេលវេលាដើម្បីដោះស្រាយបញ្ហាគឺមានពេលកំណត់!
2. ប្រសិនបើសន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់អ្នក/សម្រាប់អ្នកបោះឆ្នោតអវត្តមានមិនត្រូវបានគេរាប់៖
    a. មូលហេតុទូទៅដែលផ្ញើតាមសំបុត្រ/សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានមិនត្រូវបានគេរាប់៖
        i. **ការផ្ទៀងផ្ទាត់ហត្ថលេខា** – ហត្ថលេខានៅលើសំបុត្ររបស់អ្នកបានផ្ញើ/សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានមិនត្រូវគ្នានឹងហត្ថលេខាដែលរដ្ឋាភិបាលមាននៅក្នុងកំណត់ត្រា។
        ii. **ការមិនបានធ្វើតាមការណែនាំឱ្យបានទាំងស្រុង ឬត្រឹមត្រូវ។**
        iii. **ការមិនបានបញ្ចូលច្បាប់ចម្លងអត្តសញ្ញាណរបស់អ្នក។**
    b. សូមទូរសព្ទទៅខ្សែទូរសព្ទទាន់ហេតុការណ៍ **1-888-API-VOTE** (1-888-274-8683) ដើម្បីមើលថាតើអ្នកអាចដោះស្រាយបញ្ហាសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមាន/ផ្ញើតាមសំបុត្ររបស់អ្នកបានឬអត់។ ជំនួយត្រូវបានផ្តល់ជាភាសាអង់គ្លេស បង់ហ្គាលី ចិនកាតាំង ហិណ្ឌី កូរ៉េ ចិនកុកងឺ តាកាឡុក វៀតណាម និងអ៊ើឌូ។

**សន្លឹកឆ្នោតបណ្តោះអាសន្ន**

1. ប្រសិនបើអ្នកបានបោះឆ្នោតដោយសន្លឹកឆ្នោតបណ្តោះអាសន្ន រដ្ឋាភិបាលរដ្ឋ ឬមូលដ្ឋានរបស់អ្នកគួរតែបានផ្តល់ព័ត៌មានដល់អ្នកអំពីវិធីដែលអ្នករកមើលថាតើសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកត្រូវបានគេរាប់ឬអត់នៅពេលដែលអ្នកបោះឆ្នោត។
2. ប្រសិនបើអ្នកបានបោះឆ្នោតដោយសន្លឹកឆ្នោតបណ្តោះអាសន្ន ហើយវាមិនត្រូវបានគេរាប់ អ្នកអាចចាត់វិធានការដើម្បីឱ្យគេរាប់សន្លឹកឆ្នោតក្នុងករណីមួយចំនួន៖
    a. មូលហេតុទូទៅដែលសន្លឹកឆ្នោតបណ្តោះអាសន្នមិនត្រូវបានគេរាប់៖
        i. **ការចុះឈ្មោះអ្នកបោះឆ្នោត** – ប្រសិនបើអ្នកជឿជាក់ថាអ្នកបានចុះឈ្មោះបោះឆ្នោតហើយ ប៉ុន្តែមិនមានឈ្មោះបង្ហាញនៅលើបញ្ជីឈ្មោះអ្នកបោះឆ្នោតនៅកន្លែងបោះឆ្នោតត្រឹមត្រូវរបស់អ្នកទេ វាប្រហែលជាមានបញ្ហាជាមួយនឹងការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកដែលអ្នកអាចដោះស្រាយជាមួយមន្ត្រីបោះឆ្នោតមូលដ្ឋានរបស់អ្នកបាន។
        ii. **អត្តសញ្ញាណ** – ប្រសិនបើអ្នកភ្លេចយកឯកសារបញ្ជាក់អត្តសញ្ញាណដែលសមស្របទៅនឹងការបោះឆ្នោត ក្នុងករណីខ្លះអ្នកអាចយកវាទៅកាន់មន្ត្រីបោះឆ្នោតមូលដ្ឋានរបស់អ្នក។
        iii. **ការផ្ទៀងផ្ទាត់ហត្ថលេខា** – ប្រសិនបើហត្ថលេខារបស់អ្នកមិនត្រូវគ្នានឹងហត្ថលេខានៅលើឯកសារជាមួយកំណត់ត្រាបោះឆ្នោតទេ អ្នកអាចចាត់វិធានការក្នុងការដោះស្រាយបញ្ហានេះជាមួយនឹងមន្ត្រីបោះឆ្នោតបន្ទាប់ពីការបោះឆ្នោត។
    b. ពេលវេលាដើម្បីដោះស្រាយបញ្ហាទាំងនេះមានកំណត់។ សូមទូរសព្ទទៅខ្សែទូរសព្ទទាន់ហេតុការណ៍ **1-888-API-VOTE** (1-888-274- 8683) ដើម្បីស្វែងរកវិធី។ ជំនួយត្រូវបានផ្តល់ជាភាសាអង់គ្លេស បង់ហ្គាលី ចិនកាតាំង ហិណ្ឌី កូរ៉េ ចិនកុកងឺ តាកាឡុក វៀតណាម និងអ៊ើឌូ។

*ចង់ស្វែងយល់បន្ថែមទេ? សូមមើលធនធានបោះឆ្នោតនៅលើគេហទំព័រ www.advancingjustice-aajc.org/election2020។*